**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**នាយកដ្ឋានព័ត៌មាន**

# សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

--------

១. វាជារឿងគួរឱ្យភ្ញាក់ផ្អើលនិងខកចិត្តយ៉ាងខ្លាំង ក្រោយពីបានកត់សម្គាល់ឃើញនូវអាកប្បកិរិយាខ្វះការទូត និងមិនគោរពមួយទៀតរបស់ស្ថានទូតសហរដ្ឋអាមេរិកនៅភ្នំពេញ ចំពោះកម្ពុជាដែលជាប្រទេសម្ចាស់ផ្ទះ។ តាមរយៈការបង្ហោះសារលើទំព័រហ្វេសប៊ុកផ្លូវការរបស់ខ្លួននៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០១៩ ស្ថានទូតបានផ្សព្វផ្សាយនូវបទអត្ថាធិប្បាយខុសឆ្គង វាយប្រហារលើភាពត្រឹមត្រូវនៃការបោះឆ្នោតទូទៅនៅកម្ពុជា កាលពីឆ្នាំ២០១៨។

២. យើងនឹកស្មានមិនដល់ទាល់តែសោះថា ទង្វើវាយប្រហារដ៏គឃ្លើនបែបនេះ ដែលរំលោភបំពានទៅលើបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១ ត្រូវបានបង្កឡើងដោយស្ថានបេសកកម្មដែលតំណាងឱ្យប្រទេសដែលមានអារ្យធម៌មួយ។

៣. អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមរំលឹកសារជាថ្មីដល់ស្ថានទូតសហរដ្ឋអាមេរិកនៅភ្នំពេញ ពីភាពចាំបាច់នៃការអនុវត្តតាមមាត្រា១នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលចែងយ៉ាងច្បាស់ថា គោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយរបស់អង្គការសហប្រជាជាតិគឺ "ត្រូវកសាងទំនាក់ទំនងមិត្តភាពក្នុងចំណោមប្រជាជាតិទាំងឡាយ ដោយផ្អែកលើការគោរពគោលការណ៍នៃសិទ្ធិស្មើភាពគ្នា និងសិទ្ធិស្វ័យសម្រេចរបស់ប្រជាជន និងត្រូវចាត់វិធានការសមស្របទាំងឡាយផ្សេងទៀត ដើម្បីពង្រឹងសន្តិភាពសកល"។ លើសពីនេះទៀត មាត្រា៤១នៃអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១ ចែងយ៉ាងច្បាស់ថា៖

ក. បុគ្គលគ្រប់រូបដែលទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិបែបនេះ មានករណីកិច្ចគោរពច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ប្រទេសម្ចាស់ផ្ទះ។ ទន្ទឹមនឹងនេះ ពួកគេក៏មានករណីកិច្ចមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសនោះដែរ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ខ. និវេសនដ្ឋានទាំងឡាយរបស់ស្ថានបេសកកម្ម មិនត្រូវបានប្រើប្រាស់តាមរបៀបណាមួយ ដែលមិនស្របតាមមុខងាររបស់ស្ថានបេសកកម្ម ដូចមានចែងក្នុងអនុសញ្ញានេះ ឬដោយ វិធានច្បាប់អន្តរជាតិទូទៅផ្សេងទៀត ឬដោយកិច្ចព្រមព្រៀងពិសេសណាមួយជាធរមាន រវាងប្រទេសបញ្ជូន និងប្រទេសម្ចាស់ផ្ទះ។

ក្នុងគោលដៅនេះ គោលការណ៍សមភាពអធិបតេយ្យរបស់រដ្ឋ បូរណភាពដែនដី និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង ត្រូវតែគោរពឱ្យបានពេញលេញ។

៤. ទោះបីជាមានការអំពាវនាវរបស់ក្រុមក្រៅច្បាប់ឱ្យធ្វើពហិការបោះឆ្នោតក៏ដោយ ក៏ការបោះឆ្នោតសកលកាលពីឆ្នាំមុន មានចំនួនអ្នកចូលរួមបោះឆ្នោតរហូតដល់៨៣,០២ភាគរយ ពោលគឺជាអត្រាខ្ពស់បំផុតមួយ បើប្រៀបធៀបទៅនឹងការបោះឆ្នោតនានានៅក្នុងបណ្ដាប្រទេសដែលប្រកាន់លទ្ធិប្រជាធិបតេយ្យជាយូរមកហើយ។ ការបោះឆ្នោតនោះ បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិភាព មានសណ្ដាប់ធ្នាប់ សេរីនិងយុត្តិធម៌ ក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ពីសំណាក់អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិរាប់ម៉ឺននាក់។ លើសពីនេះទៀត តួលេខនេះក៏បញ្ជាក់ពីបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ក្នុងការចង់បានការបន្តកិច្ចអភិវឌ្ឍប្រទេសជាតិលើមាគ៌ាសន្តិភាព ស្ថិរភាព ប្រជាធិបតេយ្យ និងនីតិរដ្ឋជានិរន្តរ៍ ក៏ដូចជាការបន្តជំនឿទុកចិត្តរបស់ប្រជាជនលើគណបក្សកាន់អំណាច។ ការបដិសេធចំពោះការពិតទាំងនេះ ស្មើនឹងការវាយប្រហារទៅលើឆន្ទៈសេរីរបស់ប្រជាជនកម្ពុជាភាគច្រើនបំផុត ក៏ដូចជាលើសុច្ចរិតភាពរបស់អ្នកសង្កេតការណ៍ទាំងអស់ ដែលបានវាយតម្លៃការបោះឆ្នោតលើទីតាំងជាក់ស្ដែង។

៥. សកម្មភាពមួលបង្កាច់ឥតឈប់ឈររបស់ស្ថានទូតសហរដ្ឋអាមេរិក មិនត្រឹមតែប្រព្រឹត្តទៅផ្ទុយនឹងការខិតខំប្រឹងប្រែងបច្ចុប្បន្នប្រកបដោយសុឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងមិត្តភាពលើគ្រប់វិស័យជាមួយនឹងសហរដ្ឋអាមេរិកប៉ុណ្ណោះទេ ប៉ុន្តែក៏បានចោទជាសំណួរអំពីគោលបំណងស្មោះត្រង់របស់ស្ថានទូតសហរដ្ឋអាមេរិក ចំពោះកម្ពុជាដែលជាប្រទេសម្ចាស់ផ្ទះផងដែរ៕

ថ្ងៃ ពុធ ១៥រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៩